

តែឥឡូវនេះ ដែល
នៅក្នុងព្រះគ្រីស្ទ
យេស៊ូវ នោះអ្នករាល់
គ្នា
ដែលពីដើមនៅ
ឆ្ងាយ បានមកជិត
វិញ ដោយសារ
ព្រះលោហិតទ្រង់

**អេភេសូ២:១៣**

# ដើម្បីចូលទៅនគរឋានសួគ៌

**ដើម្បីចូលទៅនគរឋានសួគ៌** ជាការសំខាន់ដែលយើងត្រូវដឹងថា:

"**គ្រប់គ្នា**បានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ" "ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា។"
**រ៉ូម៣:២៣, ៦:២៣**

**ដើម្បីចូលទៅនគរឋានសួគ៌** ជាការលើកទឹកចិត្តយើងឲ្យដឹងថាព្រះយេស៊ូវទ្រង់មានព្រះបន្ទូលថា:

"**ខ្ញុំ**ទៅរៀបកន្លែងឲ្យអ្នករាល់គ្នា...នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ" **យ៉ូហាន ១៤:២,៣**

**ដើម្បីចូលទៅនគរឋានសួគ៌** ជាការអស្ចារ្យដែលយើងត្រូវដឹងថាព្រះយេស៊ូវទ្រង់ជា:

"ព្រះគ្រីស្ទបាន**សុគត** ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ" "ដើម្បីឲ្យទ្រង់បានបំផ្លាញអានោះ ដែលមានអំណាចលើសេចក្ដីស្លាប់ គឺជាអារក្ស ដោយទ្រង់សុគត" ឥឡូវទ្រង់ប្រកាសថា "ទ្រង់ជាព្រះដ៏រស់នៅ អញបានស្លាប់ តែមើល អញរស់នៅអស់កល្បជានិច្ចរៀងរាបតទៅវិញ អញក៏មានកូនសោនៃសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ដែរ ។" **១កូរិនថូស ១៥:៣, ហេព្រើរ២:១៤, វិវរណៈ១:១៨**

**ដើម្បីចូលទៅនគរឋានសួគ៌** ជាការសំខាន់ដែលយើងត្រូវដឹងថាសេចក្ដសង្គ្រោះគឺជាព្រះគុណឥតបង់ថ្លៃសម្រាប់អស់អ្នកមានបាបហើយផ្លាស់ប្រែ:

"ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបាន**សង្គ្រោះ** ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ" ព្រះយេស៊ូវគ្រីស្ទទ្រង់មានបន្ទូលថា៖ "ខ្ញុំជាទ្វារ បើអ្នកណាចូលតាមខ្ញុំ នេះនឹងបានសង្គ្រោះ" **អេភេសូ ២:៨, យ៉ូហាន ១០:៩**

## នេះជាក្ដីសង្ឃឹម
## សម្រាប់អ្នកអស់សង្ឃឹម



មិនថាអ្នកមានឬគ្មាន
AID S

ព្រះទ្រង់រៀបចំផ្លូវសម្រាប់អ្នក
ដើម្បីចូលទៅនគរឋានសួគ៌

# ព្រះទ្រង់ក៏បានប្រាប់ពីរបៀបដែលអ្នកអាចយកឈ្នះលើសាតាំង

| | |
|---|---|
| “គេបានឈ្នះវា... | នោះមានន័យថាវាគឺជាការដែលអាចធ្វើទៅបានសម្រាប់អ្នកដើម្បីយកឈ្នះលើសាតាំង ។ វាគឺជាសត្រូវរបស់ព្រះដែលបានចោទប្រកាន់អ្នកពីអំពើបាបនិងការបរាជ័យ ។ សាតាំងមិនចង់ឲ្យអ្នកគិតថាមានក្តីសង្ឃឹមសម្រាប់អ្នកដើម្បីចូលទៅនគរឋានសួគ៌ ។ |
| ដោយសារឈាមនៃកូនចៀម... | មានន័យថា ទោះបីជាឈាមមនុស្សរាល់គ្នាមានផ្ទុកគ្រាប់ពូជនៃការស្លាប់ផ្សេងពីគ្នា មានតែព្រះលោហិតនៃព្រះអម្ចាស់យេស៊ូគ្រិស្តដែលធ្វើឲ្យឥតសៅហ្មង។ វាជាឈាមដែលបានខ្ចាយហើយមានតម្លៃសម្រាប់អំពើបាបរបស់អ្នក។ ប្រសិនបើអ្នកជឿលើព្រះអម្ចាស់យេស៊ូគ្រិស្តសាតាំងនឹងលែងអាចចោទប្រកាន់អ្នក ហើយដោយព្រះលោហិតរបស់ព្រះយេស៊ូវនោះអ្នកត្រូវបានរំដោះឲ្យរួចពីចំណងរបស់សាតាំង ។ |
| ហើយដោយសារសេចក្តីបន្ទាល់របស់គេ | មានន័យថា អ្នកត្រូវទៅប្រកាសប្រាប់គេថាអ្នកបានសម្រេចចិត្តយកព្រះយេស៊ូវគ្រីស្ទជាព្រះសម្រាប់ផ្ទាល់ខ្លួន និងជាព្រះសង្គ្រោះរបស់អ្នក ។ |
| ក៏មិនបានស្តាយជីវិតខ្លួនដរាបដល់ស្លាប់“ *វិវរណៈ១២:១១* | មានន័យថា ដោយសារព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទសុគតសម្រាប់អ្នក ឥឡូវសេចក្តីស្រឡាញ់របស់អ្នកដែលមានចំពោះទ្រង់គឺវាធំធេងជាងជីវិតរបស់អ្នកទៅទៀត ។ សូមទូលទ្រង់នូវទំហំនៃសេចក្តីរបស់អ្នកដែលមានចំពោះទ្រង់ ៕ |

ព្រះជាម្ចាស់ទ្រង់មានផែនការតែមួយគត់សម្រាប់ការរួមសម្ព័ន្ធមេត្រីរវាង
បុរសម្នាក់ ស្ត្រីម្នាក់ដែលមានទំនាក់ទំនងនឹងគ្នា បន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ហើយ

*"ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ”*

**យ៉ូហាន៣:១៦**

ដើម្បីឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់ដែលមានចំពោះព្រះ
និងដើម្បីធានាថាអ្នកមានជីវិតអស់កល្បជានិច្ច អ្នកត្រូវ
អធិស្ឋានដល់ព្រះឲ្យអស់ពីដួងចិត្ត ។
វាសនាអស់កល្បរបស់អ្នកគឺអាស្រ័យលើការអធិស្ឋានអស់ពី
ពីដួងចិត្តរបស់អ្នក ដើម្បី
ឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់អស្ចារ្យរបស់ព្រះ។ សូមអ្នក
មើលលំនាំសេចក្តីអធិស្ឋាន ។

## សេចក្តអធិស្ឋានរបស់ខ្ញុំ

ព្រះដ៏មានឫទ្ធានុភាព ទូលបង្គំសូមក្រាបនៅចំពោះទ្រង់ ហើយសារភាពថា ខ្ញុំជាអ្នកមានបាប ។ ទូលបង្គំសមនឹងស្លាប់ ដោយអំពើបាបរបស់ទូលបង្គំ ។ អរព្រះគុណព្រះជាម្ចាស់ដែលប្រទានព្រះយេស៊ូវមកសុគតនៅលើឈើឆ្កាងជំនួសអំពើខ្ញុំ ។ ឥឡូវ ខ្ញុំបែរចេញពីអំពើបាប ហើយដើរដោយជំនឿជាមួយព្រះយេស៊ូវ ជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះ ។ សូមអត់ហើយសម្អាតចិត្តនិងជីវិតរបស់ខ្ញុំ ។ ដោយអំណាចនៃលោហិតដ៏ថ្លៃថ្លារបស់ព្រះយេស៊ូវ ខ្ញុំសូមបោះបង់ភក្តីភាពដែលមានចំពោះសាតាំង ។ ឥឡូវខ្ញុំយាងទ្រង់មកគត់ក្នុងចិត្ត ជីវិត និងបំពេញខ្ញុំដោយព្រះវិញ្ញាណរបស់ទ្រង់ ។ អរគុណទ្រង់ដែលបានអត់ទោស! អរគុណទ្រង់ដែលខ្ញុំបានកើតជាថ្មី ហើយថ្ងៃណាមួយខ្ញុំនឹងរស់នៅជាមួយទ្រង់នៅឋានសួគ៌ ។ អាម៉ែន

Trans World Radio • P.O. Box 8700, Cary, NC 27512, USA
Phone: 919-460-3700 or 800-456-7897 (7TWR) ©CCIM